**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ**
**នាយកដ្ឋានធានារ៉ាប់រង និង សោធន**

*រាជធានីភ្នំពេញ ថ្ងៃទី០១ខែ ធ្នូ ឆ្នាំ២០១៤*

# សេចក្តីជូនដំណឹង
## អំពីសិក្ខាសាលាផ្សព្វផ្សាយស្តីពី “អត្ថប្រយោជន៍នៃការធានារ៉ាប់រង” នៅខេត្តព្រះសីហនុ

នាយកដ្ឋានធានារ៉ាប់រង និង សោធន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជម្រាបជូនសាធារណជន និងក្រុមហ៊ុនធានារ៉ាប់រងទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា នៅក្នុងយន្តការទីផ្សារធានារ៉ាប់រងនៃយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ បានកំណត់គោលដៅរយៈពេលខ្លីស្តីពីការកសាងផែនការដើម្បីធ្វើយុទ្ធនាការ បង្កើនការយល់ដឹងអំពីធានារ៉ាប់រងដល់ប្រជាពលរដ្ឋអោយបានទូលំទូលាយ ។ នាយកដ្ឋានធានារ៉ាប់រង និង សោធន នឹងរៀបចំសិក្ខាសាលាផ្សព្វផ្សាយការយល់ដឹងស្តីពីអត្ថប្រយោជន៍នៃការធានារ៉ាប់រង ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ នៅសណ្ឋាគារ ឯករាជ្យ ខេត្តព្រះសីហនុ ។ ចំពោះដំណើរការនៃការរៀបចំសិក្ខាសាលានេះ នាយកដ្ឋានធានារ៉ាប់រង និង សោធន សូមជម្រាបផងដែរថា ក្នុងន័យចូលរួមសហការជម្រុញការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនធានារ៉ាប់រងទាំងឡាយអាចចូលរួមសហការឧបត្ថម្ភ ឬដាក់តាំងបង្ហាញផលិតផលធានារ៉ាប់រងនៅក្នុងអង្គសិក្ខាសាលានេះផងដែរ ។ សូមមេត្តាទំនាក់ទំនងមកកាន់ **កញ្ញា កែវ សម្ផស្ស** ទូរស័ព្ទលេខ ០៩២ ៣៨៥ ៦០៨ ឬ អ៊ីម៉ែល keosomphors3@gmail.com ឲ្យបាន មុនថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ ។

**នាយកដ្ឋាន**
**ធានារ៉ាប់រង និង សោធន**